# ចុះឈ្មោះដើម្បីនិយាយនៅពេលគណៈកម្មការកែទម្រង់សាលាប្រជុំ
# ការអត្ថាធិប្បាយរបស់សាធារណៈជន

**តាមជំពូក៦: ការអត្ថាធិប្បាយរបស់សាធារណៈជន នៃច្បាប់ ០០៦ របស់គណៈកម្មការកែទម្រង់សាលា: ការប្រជុំ:**

ក. គណៈកម្មការកែទម្រង់សាលាអះអាងជាថ្មីនូវសិទ្ធិរបស់សាធារណៈជន ដើម្បីបញ្ចេញការអត្ថាធិប្បាយទៅកាន់គណៈកម្មការកែទម្រង់សាលា ពីរឿងដែលមានការបារម្ភទូទៅ តាមសកម្មភាពជាពិធីការរបស់គណៈកម្មការកែទម្រង់សាលា ឬតាមការពិភាក្សារឿង នៅមុខ ឬប្រហែលជានៅមុខគណៈកម្មការកែទម្រង់សាលា។

ខ. សាធារណៈជននឹងផ្តល់ការអត្ថាធិប្បាយទៅគណៈកម្មការកែទម្រង់សាលាតាមការសរសេរ ហើយយកទៅការិយាល័យគណៈកម្មការកែទម្រង់សាលា ដែលស្ថិតនៅ 440 North Broad Street, Suite 101, Philadelphia, PA 19130។

គ. សាធារណៈជននឹងផ្តល់ការអត្ថាធិប្បាយទៅគណៈកម្មការកែទម្រង់សាលា តាមការចុះឈ្មោះដើម្បីនិយាយទៅកាន់គណៈកម្មការកែទម្រង់សាលានៅពេលប្រជុំធម្មតា ឬពេលប្រជុំពិសេស។ ទម្រង់ការសម្រាប់និយាយទៅកាន់គណៈកម្មការកែទម្រង់សាលា មានដូចតទៅ:

i. បុគ្គលម្នាក់ៗត្រូវតែចុះឈ្មោះនៅក្រសួងអប់រំ ការិយាល័យទំនាក់ទំនងជាមួយមាតាបិតា គ្រួសារ និងសហគមន៍ (School District Office of Parent, Community & Family Engagement) ដោយទូរស័ព្ទទៅ 215-400-4180 កុំឲ្យហួសម៉ោង 4:30 ល្ងាច មុនថ្ងៃប្រជុំដែលពួកគាត់ចង់ផ្តល់ការអត្ថាធិប្បាយដល់គណៈកម្មការកែទម្រង់សាលា។

ii. បុគ្គលម្នាក់ៗត្រូវតែចុះឈ្មោះរបស់ពួកគាត់ដោយផ្ទាល់ ហើយមិនអាចចុះឈ្មោះឲ្យអ្នកផ្សេងទៀតបានទេ។

iii. បុគ្គលណាដែលជាតំណាងរបស់អង្គការណាមួយ ត្រូវតែប្រាប់ឈ្មោះអង្គការនោះ នៅពេលចុះឈ្មោះ ហើយអង្គការនិមួយៗមិនអាចចុះឈ្មោះដើម្បីឡើងនិយាយលើសពីម្នាក់បានទេ នៅពេលប្រជុំម្តងៗ។

iv. បុគ្គលម្នាក់ៗត្រូវតែផ្តល់ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទពេលថ្ងៃ និងកម្មវត្ថុដែលគាត់ចង់និយាយទៅកាន់គណៈកម្មការកែទម្រង់សាលា។

v. បុគ្គលម្នាក់ៗត្រូវតែនាំមកនូវការអត្ថាធិប្បាយដែលបានសរសេរចំនួនប្រាំពីរចម្លង មកកាន់អង្គប្រជុំ

1. បុគ្គលម្នាក់ៗមិនអាចនិយាយលើសពីបីនាទីបានទេ។

2. គេនឹងមិនអនុញ្ញាតឲ្យនិយាយរឿងដូចគ្នាលើសពីប្រាំមួយនាក់បានទេ តែអ្នកទាំងនោះអាចទុកការអត្ថាធិប្បាយតាមការសរសេរឲ្យគណៈកម្មការកែទម្រង់សាលាពិនិត្យមើល ដោយគ្មានកំណត់។

3. គេនឹងបដិសេធបុគ្គលណាដែលប៉ុនប៉ងអធិប្បាយ ឬត្អូញត្អែ អំពីចរិយា ឬការធ្វើអ្វីមួយរបស់អ្នកធ្វើការឲ្យក្រសួងអប់រំនៅសាលាណាមួយ ហើយគេនឹងបង្គាប់ឲ្យបុគ្គលនោះនិយាយទៅកាន់អភិបាលក្រសួងអប់រំណាម្នាក់ដែលជាអ្នកទទួលខុសត្រូវក្នុងរឿងនោះ។

4. គេនឹងបដិសេធបុគ្គលណាដែលប៉ុនប៉ងនិយាយអំពីរឿងផ្ទាល់ខ្លួនរបស់អ្នកណាម្នាក់ ទោះជាអ្នកនោះ នៅ ឬមិននៅទីនោះក៏ដោយ។ ហើយ

5. គេនឹងបដិសេធបុគ្គលណាដែលប្រើពាក្យថោកទាប ឬប្រមាថមើលងាយ ហើយគេនឹងសុំឲ្យអ្នកនោះចាកចេញពីអង្គប្រជុំ។

vi. តាមការយល់ឃើញរបស់គាត់ លោកប្រធានកែទម្រង់សាលាអាចផ្អាក ឬប្តូរ ទម្រង់ការណាមួយដែលទាក់ទងដល់ការនិយាយទៅកាន់គណៈកម្មការកែទម្រង់សាលា។